ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

កំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃ ២ទ្ធ ១៣ កើត ខែ ចេត្រ ឆ្នាំ ឆលាង ត្រីស័ក ព.ស. ២៥៦៦

លេខ ២០២/២៣ ...ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២៣

សេចក្តីជូនដំណឹង

ស្តីពី

មហាសន្និបាតភាគហ៊ុនិកលើកទី ៨ របស់កំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" របស់ ក. ស. ភ. ទាំងអស់មេត្តាជ្រាបថា យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក.ស.ភ. ក្នុងសម័យប្រជុំលើកទី៤ អាណត្តិទី៨ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ក. ស. ភ. នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៨ តាមការកំណត់ដូចខាងក្រោម÷

១. កាលបរិច្ឆេទកំណត់ទុក (Record Date) : **ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣**

២. កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៨ : **ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៩:00 នាទីព្រឹក**

៣. ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៨ : **សាលប្រជុំជាន់ទី៣ នៃអគារដ្ឋបាលចំណតផែកុងតឺន័រ LM១៧** ដែលស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៤. របៀបវារៈនៃមហាសន្និបាតភាគហ៊ុនិកលើកទី៨ រួមមាន :

ក. របាយការណ៍ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងការលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣

ខ. សំណើសុំពិនិត្យ និងអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២

គ. សំណើសុំពិនិត្យ និងអនុម័តប្រាក់លាភការក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០២៣ និងឆ្នាំបន្តបន្ទាប់រហូតដល់បញ្ចប់អាណត្តិទី៨។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក. ស. ភ.) ឬ អាចអញ្ជើញមកទទួលលិខិតអញ្ជើញនៅទីស្នាក់ការកណ្តាលរបស់ ក. ស. ភ. ដែលមានអាសយដ្ឋាននៅ អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅរៀងរាល់ម៉ោងធ្វើការ ចាប់ពី **ថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣**។

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ ពីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្ដីជូនដំណឹងខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាបញ្ជាក់អំពីការចូលរួមទៅ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈសារអេឡិចត្រូនិច និងលេខទំនាក់ទំនង ដូចបញ្ជាក់ជូនខាងក្រោម ចាប់ពី **ថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣** នៅវៀងរាល់ម៉ោងធ្វើការ។

❖ **<u>បញ្ជាក់</u>** : **ភាគហ៊ុនិកដែលអញ្ជើញមកចូលរួមមហាសន្និបាតភាគហ៊ុនិក សូមភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូនអ្នកធ្វើជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៨ របស់ ក.ស.ភ.។**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក **ធនាគារ អេស៊ីលីដា ភីអិលស៊ី** និង**កំពង់ផែស្វយ័តភ្នំពេញ** តាមអាសយដ្ឋាន និងលេខទំនាក់ទំនង ដូចខាងក្រោម :

១.ធនាគារ អេស៊ីលីដា ភីអិលស៊ី

- អាសយដ្ឋាន : ជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ : (៨៥៥) ២៣ ៩៩៨ ៧៧៧
- ទូរសារ : (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ : (៨៥៥) ១៥ ៩០០ ៥៣៨
  (៨៥៥) ១៥ ៨០០ ៦៦៣
  (៨៥៥) ៦១ ២៨៧ ៧៦៦
- សារអេឡិចត្រូនិក : huot.sophy@acledabank.com.kh

២.កំពង់ផែស្វយ័តភ្នំពេញ

- អាសយដ្ឋានអគារលេខ ៦៨៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទដៃ : ០១០ ៨៨៨ ៣៦៧/០១០ ៨៨៨ ៨៩៨
- សារអេឡិចត្រូនិក : ppapmpwt@online.com.kh

៩. គណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ៨

ប្រធាន

ហ៊ីង-ហ្ការី

<u>ចម្លងជូន</u>÷
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-និយ័តករមូលបត្រកម្ពុជា (ន. ម. ក)
-ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ. ម. ក)
-សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.
-សវនករផ្ទៃក្នុងរបស់ ក. ស. ភ.
-សវនករឯករាជ្យរបស់ ក. ស. ភ. - ក្រុមហ៊ុន BDO
<u>-ដើម្បីគោរពជូនជ្រាប-</u>
-ធនាគារ អេស៊ីលីដា ភីអិលស៊ី
(ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)
<u>-ដើម្បីសហការផ្សព្វផ្សាយ-</u>
-ឯកសារ-កាលប្បវត្តិ